# ការសម្ភាសរបស់លោកយាយ ហ៊ុត ភា

កៈ អ្នកសម្ភាសឈ្មោះអេង ដាលីន ខៈ អ្នកអោយគេសម្ភាសឈ្មោះ ហ៊ុត ភា

## ការសង្ខេបប្រវត្តិរបស់លោកយាយ ហ៊ុត ភា

លោកយាយ ហ៊ុត ភា មានអាយុ៧៧ ឆ្នាំនៅក្នុងឆ្នាំ២០១៨ មានទីលំនៅបច្ចុប្បន្ន នៅភូមិបន្ទាយឈើ ឃុំទឹកវិល ស្រុកសៀមរាប ខេត្តសៀមរាប។

កៈ
ជាដំបូងសូមជម្រាបសួរដល់លោកយាយដែលលោកយាយបានអនុញ្ញាតិអោយរូបនាងខ្ញុំមកសម្ភាសលោកយាយ ទាក់ទងពីប្រវត្តិរបស់លោកយាយហាសណាំលោកយាយ។ ចាំ! អើ! ពួកយើងមកសម្ភាសលោកយាយហើយ
ពួកយើងចងក្រងប្រវត្តិរបស់លោកយាយហើយទុកអោយកូនចៅជំនាន់ក្រោយរបស់លោកយាយបានស្តាប់ហាសណាំ បានស្តាប់នៅអើ! ប្រវត្តិរបស់លោកយាយ ហើយនាងខ្ញុំឈ្មោះ អេង ដាលីន តំណាងអោយសាកលវិទ្យាល័យមួយនៅអាមេរិចដែលមានឈ្មោះថាBYU ហើយនៅថ្ងៃនេះ ថ្ងៃទី២៤ ខែ៨ ២០១៨
ជាថ្ងៃដែលខ្ញុំមកសម្ភាសលោកយាយហាសណាំលោកយាយ។

ខៈ ចាំ!

កៈ លោកយាយនៅភូមិហ្នឹង មានឈ្មោះភូមិអីដែរលោកយាយ?
លោកយាយខិតមកនេះបានទេ ភូមិអីគេដែរ?

ខៈ ភូមិបន្ទាយឈើ...

កៈ លោកយាយអាចនិយាយអោយខ្លាំងៗបានទេ?

ខៈ ភូមិបន្ទាយឈើ។

កៈ ស្រុកអីៗឃុំអី?

ខៈ ភូមិបន្ទាយឈើៗ ឃុំទឹកវិល។

កៈ ឃុំទឹកវិល?

ខ៖ ខេត្តសៀមរាប។

ក៖ ខេត្តសៀមរាប។ ចាំ! ចឹងលោកយាយអើ! សូមនេះ...លោកយាយ ចឹងឈ្មោះពេញរបស់លោកយាយឈ្មោះអីដែរលោកយាយ?

ខ៖ ឈ្មោះពេញ?

ក៖ ឈ្មោះពេញ ឈ្មោះនាមត្រកូលរបស់លោកយាយហាសណាំ?

ខ៖ ខ្ញុំឈ្មោះនេះហើយ បានថា ហ៊ុត ភា។

ក៖ ហ៊ុត ភា?

ខ៖ ចាំ!

ក៖ លោកយាយ ឈ្មោះហ៊ុត ភា?

ខ៖ ចាំ!

ក៖ ចាំ! លោកយាយឥឡូវលោកយាយមានអាយុប៉ុន្មានឆ្នាំដែរលោកយាយ?

ខ៖ ខ្ញុំ?

ក៖ លោកយាយខិតមកនេះបន្តិចបានទេ ដោយសារតែយើងអត់ឮ។

ខ៖ ៧៧!

ក៖ ៧៧ឆ្នាំ?

ខ៖ ចាំ!

ក៖ ចុះលោកយាយឆ្នាំច័ន្ទគតិ គឺអើ...ជូត ឆ្លូវ ខាល ថោះ លោកយាយឆ្នាំអីដែរលោក?

ខ៖ ខ្ញុំ?

ក៖ ចាំ!

ខ៖ ខ្ញុំឆ្នាំមមី។

ក៖ ឆ្នាំមមី?

ខ៖ ចាំ!

ក៖ ឆ្នាំមមី អាយុ៧៧ឆ្នាំ ហើយចុះអើ! លោកយាយកើតនៅភូមិណាដែរលោកយាយ?

ខ៖ ខ្ញុំកើតនៅភូមិបន្ទាយឈើនេះឯង។

ក៖ ភូមិបន្ទាយឈើ នៅផ្ទះហ្នឹងមែន?

ខ៖ ចាំ!

ក៖ អញ្ចឹងផ្ទះហ្នឹងតាំងពីដូនតាយាយមកហោស?

ខ៖ ដូនតា ប៉ុនឆេះកាលប៉ុលពតម្ដងមួយហើយ។

ក៖ អញ្ចឹង!

ខ៖ ដល់នេះវាធ្វើជាក្រោយប៉ុលពតទៀតមក ផ្ទះឆេះអស់ហើយ។

ក៖ ចាំ! ចឹងលោកយាយមានបងប្អូនប៉ុន្មាននាក់លោកយាយ?

ខ៖ ខ្ញុំបងប្អូនមានតែ៩នាក់ទេ។

ក៖ ៩នាក់?

ខ៖ ក្រៅពីហ្នឹងងាប់អស់ហើយ។

ក៖ លោកយាយអើ...

ខ៖ បងប្អូនខ្ញុំងាប់អស់ហើយ។

ក៖ លោកយាយអើ! អាចរៀបរាប់ឈ្មោះបងប្អូនលោកយាយបានទេលោកយាយ?

ខ៖ រាប់បាន ប៉ុននៅសល់តែមួយ។

ក៖ ចាំ! រៀបរាប់ទាំងអស់មក? រៀបរាប់ឈ្មោះទាំងអស់មកចាំនិយាយ?

ខ៖ អាងាប់ហ្នឹងរាប់ដែរហោស?

ក៖ ចាំ! រាប់ទាំងអស់មក?

ខ៖ អើ! រាប់ម៉េចអស់ រាប់ៗតែអារស់បានហើយ នៅសល់តែ...នៅសល់មួយ
នៅសល់ឈ្មោះអីទេ ឈ្មោះ ហ៊ុត គល់។

ក៖ ហ៊ុត គល់?

ខ៖ ហ៊ុត គល់ ចាំ! មួយហ្នឹងឯង នៅសល់តែមួយបើនិយាយ។

ក៖ ហើយចុះលោកយាយជាកូនបងក៏កូន...?

ខ៖ ខ្ញុំកូនកណ្ដាល ងាប់អស់ហើយបងប្អូនខ្ញុំនោះ។
បងប្អូនខ្ញុំងាប់អស់នៅសល់មួយហ្នឹងឯង។

ក៖ ចឹងហោសលោកយាយ?

ខ៖ សម័យប៉ុល ពត។

ក៖ ចាំ! ចឹងអើ!
ចឹងនៅពេលបងប្អូនលោកយាយស្លាប់ជំនាន់ប៉ុលពតគាត់មានអាយុប្រហែលជាប៉ុន្មានឆ្នាំដែរ?

ខ៖ ទេអាយុមិនសូវច្រើនទេ ប៉ុល ពត កាលណោះ អាយុប្រហែលជាម្ភៃជាង
ម្ភៃជាងមិនសូវចាំអាយុដែរ។ចាំ!

ក៖ លោកយាយអាចមានប្រសាសន៍ព្ទៗតិចហាសណាស់ លោកយាយចាំ!

ខ៖ ចាំ!ប្រហែលជាអាយុម្ភៃ។

ក៖ ចាំ! ចឹងនៅពេលដែលពួកគាត់នៅរស់ហាស
លោកយាយមានចងចាំសាច់រឿងថាជាមួយពួកគាត់ធ្លាប់ទៅស្រែទៅអីជាមួយគ្នាទេលោកយាយ?

ខ៖ ចាំ! ធ្វើស្រែធ្វើស្រែចម្ការជាមួយគ្នា ដកស្ទូងជាមួយគ្នា។

ក៖ សប្បាយទេពីអង្កាលណុងនៅក្មេង?

ខ៖ ចាំ! កាលពីក្មេងសប្បាយហ្នឹងឯង ហើយដល់សព្វថ្ងៃក៏នៅបែកគ្នាទៅក៏ អានៅរស់នោះ
ក៏វាមិនបាននៅជាមួយខ្ញុំ នៅឆ្ងាយនោះទៀត។

កៈ គាត់នៅណាដែរលោកយាយ?

ខៈ នៅឯភូមិគោកស្នួលឯណោះ។

កៈ គោកស្នួលនៅខេត្តណា?

ខៈ ខេត្តយើងនេះឯង ប៉ុន្តែនៅស្រុកឆ្ងាយ ត្បូងស្រុកខ្នាតឯណោះ។

កៈ ចឹងណ៎យាយ?

ខៈ ចា៎! នៅមួយនោះឯង។

កៈ ចឹង! គាត់ប្រកបមុខរបរអីដែរឥឡូវ?

ខៈ អត់មានធ្វើអីទេ ចាស់ដូចខ្ញុំចឹងនៅតែផ្ទះ។

កៈ ចា៎!

ខៈ ចា៎!

កៈ ចុះលោកយាយ ម្ដាយលោកយាយឈ្មោះអីដែរ លោកយាយ?

ខៈ ម្ដាយខ្ញុំស្លាប់យូរហើយ គាត់អាយុ៩០ណោះ។

កៈ ចា៎! តែគាត់ឈ្មោះអីដែរ?

ខៈ ចា៎! គាត់ឈ្មោះផៃ។

កៈ ត្រកូលអីដែរ?

ខៈ ឃឹម!

កៈ ឃឹម?

ខៈ ធីម!

កៈ ធីម ផៃ?

ខៈ ចា៎!

កៈ ហើយចុះឪពុករបស់លោកយាយ?

ខ៖ លោកឪពុកខ្ញុំនោះ ធីមដែរ ឪពុកគាត់ណុងឯង ធឹម ផែន នោះ។

ក៖ ឪពុករបស់លោកយាយហាស?

ខ៖ ឪពុកយាយម៉ែទៅទៀតនោះ?

ក៖ អត់ទេ! ចង់និយាយថាម្ដាយ លោកយាយមិនមានម្ដាយមានឪពុក?

ខ៖ ចា៎ !

ក៖ ម្ដាយរបស់លោកយាយមានឈ្មោះអី?

ខ៖ ម្ដាយខ្ញុំឈ្មោះផៃ។

ក៖ ផៃ?

ខ៖ ចា៎!

ក៖ គាត់ត្រកូលអីដែរ?

ខ៖ ត្រកូលធីមហ្នឹងឯង។

ក៖ ធីម ផៃ?

ខ៖ ចា៎!

ក៖ ហើយចុះឪពុកលោកយាយវិញ?

ខ៖ ឪពុកខ្ញុំនេះ?

ក៖ ចា៎!

ខ៖ ឈ្មោះ ហ៊ុត នេះឯង។

ក៖ គាត់ឈ្មោះអីត្រកូលគាត់?

ខ៖ ហ៊ុត!

ក៖ ហ៊ុត ត្រកូលគាត់ ត្រកូលគាត់ហាស?

ខ៖ ត្រកូលតាហ៊ុតហោស?

កៈ ចាំ! ត្រកូលពេញចឹងហាស អត់អីទេ បើនេះអត់អីទេ?

ខៈ ត្រកូលខ្ញុំហ៊ុតនេះឯង ប្តីយាយផៃនេះឯង យាយផៃម៉ៃខ្ញុំនេះឯង។

កៈ ចាំ! ចឹងអើ! ឪពុកលោកយាយឈ្មោះហ៊ុត?

ខៈ ចាំ !

កៈ ចាំ! ចឹងអើ! ពួកគាត់ស្លាប់យូរហើយនោះលោកយាយ?

ខៈ យូរហើយ ចាំ!

កៈ ពួកគាត់ស្លាប់តាំងពីអាយុប៉ុន្មានដែរ?

ខៈ គាត់ស្លាប់តាំងពីគាត់អាយុ៥០ ឪខ្ញុំ។ ចាំ!

កៈ ចឹងហើយចុះម្តាយ?

ខៈ ម្តាយទើបស្លាប់ហើយទេ ប៉ុន្តែម្ភៃឆ្នាំហើយដឹង អាយុ៩០។

កៈ ចុះពេលឪពុកលោកយាយស្លាប់ លោកយាយអាយុប៉ុន្មាន?

ខៈ ខ្ញុំទើបបានគ្រួសារ អាយុប្រហែលមិនទាន់ដល់ម្ភៃផង ដប់ប្រហែលដប់ប្រាំបួន ដប់ប្រាំបួនឆ្នាំ។

កៈ អូចាំ! ចុះលោកយាយមានដឹងថាឪពុករបស់លោកយាយឆ្នាំអីទេ ឆ្នាំជូត ឆ្លូវ ខាល ថោះហាស?

ខៈ អូ! យូរណាស់ហើយដោយសារទៅឆ្ងាយ។

កៈ ចាំ!

ខៈ យូរហើយ ចាំ។

ក ចាំ! យាយចាំ!

ខៈ ចាំ! យូរណាស់!

កៈ ហើយចុះអើ! ដឹងថាឪពុករបស់លោកយាយ និងម្តាយរបស់លោកយាយអ្នកស្រុកណា? អ្នកដើម កំណើតមកពីណាហាសលោកយាយ?

ខ៖ ដើមកំណើតគាត់នៅភូមិសណ្ដាន់។ ចាំ! នៅឃុំទឹកវិលៗ។

ក៖ ទាំង២នាក់ហោស?

ខ៖ ចាំ!

ក៖ ចាំ លោកយាយ! លោកយាយចឹងអើ! សម្រាប់លោកយាយនៅពីក្មេងហាស
តើឪពុកម្ដាយរបស់លោកយាយរកស៊ីអីដែរដើម្បីចិញ្ចឹមកូនៗ?

ខ៖ ធ្វើស្រែចម្ការ ធ្វើស្រែយើងអត់ដែលបានទៅជួញដូរអីណាទេអ្នកក្រទេណាំ។

ក៖ ចាំ!

ខ៖ ចាំ! អ្នកក្រធ្វើតែស្រែ ទៅអាទីនេះតិចទៅមិនសូវចេះដែរពីដើមនោះ។

ក៖ ហ្នឹងហើយ!

ខ៖ មិនសូវមានដែរ អត់សូវមានទេ
យើងពីដើមប៉ុនបើថាធ្វើស្រែក៏បោចស្លៀកធ្វើជាលនោះឯង។ ចាំ!
ធ្វើជាលចិញ្ចឹមកូនប៉ុណ្ណឹងឯង។

ក៖ ចាំ! ហើយចុះបើម្ដាយវិញ?

ខ៖ ម្ដាយក៏ដូចតែគ្នា។ ចាំ! រកស៊ីដូចតែគ្នា
មិនដែលបានទៅជួញព្រៃ(ដូចជាក្រណាត់សូត្រ)ណាទេ។

ក៖ ចាំ! ចុះបើឪពុករបស់លោកយាយវិញកាចឬមួយក៏ស្លូតលោកយាយ?

ខ៖ ស្លូតណាស់! ចាំ!

ក៖ ស្លូតហាសណាំ?

ខ៖ ចាំ!

ក៖ ស្រឡាញ់កូនទេ?

ខ៖ ចាំ! ស្រឡាញ់កូន។ ម៉ែក៏ស្រឡាញ់កូនដែរ។

ក៖ ហើយចុះម្ដាយរបស់យាយគាត់ស្លូតឬមួយក៏កាច?

ខ៖ ស្លូតដែរ គាត់ស្លូតទាំងអស់គ្នា។

ក៖ ចាំ! ចឹងនៅពេលដែលពួកគាត់នៅរស់ហាស លោកយាយដែលទៅណាអីជាមួយគាត់ធ្លាប់ទៅលេងខេត្តណា ខេត្តណាជាមួយគាត់ទេ?

ខ៖ ខ្ញុំមិនដែលបានទេ មិនដែលដើរទៅណាទេ។ យើងពីដើមមិនស្រួលទេ មិនស្រួលដែលមានគេដើរដូចសព្វថ្ងៃ មានគេជិះឡានជិះអី។ មិនដើលមានអីជិះទេ តែដើរ។ តែដើរ ទៅណាដើរ មិនដែរបានដើរទៅណាទេ។

ក៖ អត់ដែលបានទៅភ្នំពេញអីនឹងគេទេនេះយាយ?

ខ៖ អត់ទេ មិនដែលឃើញទេក្មួយអើយ មិនដែលឃើញភ្នំពេញ ភ្នំពេញឮតែគេថាមិនដែលដឹងថាភ្នំពេញម៉េច។

ក៖ ចាំ លោកយាយ!

ខ៖ ចាំ!

ក៖ ហើយចុះលោកយាយមានចាំឈ្មោះតាយាយខាងម្ដាយទេលោកយាយតាយាយខាងម្ដាយមានចាំទេ?

ខ៖ តាខាងម្ដាយ?

ក៖ ចាំ!

ខ៖ ម្ដាយខ្ញុំ តាហ្នឹងធឹមតើ១ ធឹម ផៃ ហ្នឹងឯងឪពុកពួកគាត់ហ្នឹង។

ក៖ ធឹម ផៃ?

ខ៖ ធឹម ផៃ ហ្នឹងឯង ឪគាត់។

ក៖ ហើយចុះម្ដាយគាត់វិញ?

ខ៖ ម្ដាយក៏ឈ្មោះធឹមដូចគ្នា។

ក៖ ធឹមដូចគ្នា?

ខ៖ ចាំ!

ក៖ ហើយចុះបើខាងឪពុកតាយាយខាងឪពុកចាំទេ?

ខ៖ អត់! អត់ចាំទេខ្ញុំអត់បានដឹងទេ ព្រោះគាត់…ខ្ញុំនៅតូច ខ្ញុំនៅតូចដែរអត់ដឹងទេ។

ក៖ ចាំ! អត់ដឹងទេណោះលោកយាយ។ ចាំ! ហើយចុះលោកយាយ ក្រុមគ្រួសាររបស់លោកយាយមានអ្នកណាដូចថាកូនៗលោកយាយដែលមានអ្នកនៅណា មានអ្នកណានៅខេត្តហាសលោកយាយ?

ខ៖ នៅតែនេះឯង នៅតែស្រុកសៀមរាបនេះឯង។

ក៖ អត់មាននៅខេត្តផ្សេងអីទេណោះ?

ខ៖ អត់ទេ!

ក៖ ហើយចុះមានសាច់ញាតិណាដែលនៅប្រទេសក្រៅអីទេលោកយាយ?

ខ៖ ហ្វាំ! ស្លាប់ហើយ! មិនដែលមានទេ មិនដែលមាននៅប្រទេសទេ។

ក៖ ចាំ! ហើយចុះអើ! ស្វាមីរបស់លោកយាយឈ្មោះអីដែរលោកយាយ?

ខ៖ លោកនោះណុង?

ក៖ ចាំ!

ខ៖ ឈ្មោះថាគាំ។

ក៖ តាគាំ ត្រកូលអីដែរលោកយាយគាត់?

ខ៖ ឡឹង។

ក៖ អូយ! ស្ដាប់អត់សូវបានទេ។

ខ៖ តាឡឹង!

ក៖ ឡឹង គាំ!

ខ៖ ចាំ!

កៈ ឡឹង គាំ! ចាំ! ហើយចុះលោកយាយរៀបការតាំងពីឆ្នាំណាដែរលោកយាយ?

ខៈ អត់ស្គាល់ផង អត់បានចំណាំ។

កៈ អត់ចំណាំ?

ខៈ ចាំ!

កៈ តាំងពីសម័យណាដែរ? ចំណាំទេ?

ខៈ តាំងពីសម័យយូរហើយ តាំងពីខ្ញុំអាយុដប់ប្រាំបីណោះ។

កៈ ដប់ប្រាំបី?

ខៈ ចាំ! ដូចជាឆ្នាំណា ខ្ញុំអត់បានជាស្រាវជ្រាវផង។

កៈ ហើយចុះលោកយាយ
ហើយលោកយាយដឹងតែលោកយាយកើតនៅឆ្នាំណាទេលោកយាយ?

ខៈ មិនដឹង!

កៈ ចឹងលោកយាយឥឡូវអាយុ៧៧ឆ្នាំ?

ខៈ ចាំ!

កៈ ៧៧ឆ្នាំ...

ខៈ មិនដឹងជាកើតពីអង្កាលណា  ខ្ញុំក៏មិនបានជាចាប់អារម្មណ៍ដែរ។

កៈ កើតឆ្នាំ១៩៤១!

ខៈ អើ! ប៉ុណ្ណោះឯង។

កៈ ចាំ! កើតពីឆ្នាំ១៩៤១ ហើយលោកយាយរៀបការឆ្នាំ អើ!
លោកយាយរៀបការអាយុប៉ុន្មាន?
ខៈ ១៨ឆ្នាំ!

កៈ ១៨! លោកយាយការឆ្នាំ១៩៥៩!

ខ៖ អើ! ប៉ុណ្ណោះឯងបើយើងមិនបានមិនបានជាស្រាវជ្រាវហាសណាំ
បើយើងនៅស្រុកស្រែ។

ក៖ ១៨ឆ្នាំដែលលោកយាយរៀបការចឹង។ ហើយចុះលោកតាអាយុប៉ុន្មានដែរលោកយាយ?

ខ៖ ៧៨! បងខ្ញុំ។

ក៖ ៧៨?

ខ៖ ចាំ!

ក៖ គាត់មានអាយុ៧៨ឆ្នាំចុះ។ លោកយាយអើ! មានកូនប៉ុន្មានដែរលោកយាយ?

ខ៖ ខ្ញុំមានកូន៦ ប៉ុនងាប់អស់ នៅសល់តែ៤ទេ។

ក៖ ចឹង?

ខ៖ ចាំ!

ក៖ អើ! បានអាយុប៉ុន្មានដែរទើបស្លាប់កូន?

ខ៖ អូ៎! ស្លាប់ពីតិចពីតូច ដូចថាកូនង៉ាហាសណាំ។ ស្លាប់កូនង៉ា ទើបបាន២ខែ ១ខែអីណា
ទៅនៅសល់ តែ៤ទេ។

ក៖ អញ្ចឹង?

ខ៖ ចាំ!

ក៖ ហើយចុះឥឡូវពួកគាត់មានអាយុប៉ុន្មានឆ្នាំហើយលោកយាយ?

ខ៖ ពួកគាត់?

ក៖ ចាំ!

ខ៖ ពួកគាត់មានអាយុហាលើសហើយ។

ក៖ ហាលើសហើយហោស?

ខ៖ ចាំ! ហាប្រាំបីហាអីទៅហើយ។

កៈ ហើយចុះកូនដែលនៅសល់ហ្នឹងគាត់អាយុប៉ុន្មាន?

ខៈ កូននៅសល់? ខ្លះសែ បងបន្ទាប់នោះ៥៨ អាក្រោយមកទៀតនោះប្រហែលជា៥៦។

កៈ ពួកគាត់នៅណាដែរ? នៅហ្នឹងតើ?

ខៈ នៅៗភូមិនេះឯង តែគេនៅនោះ។ ចាំ!

កៈ ពួកគាត់ប្រកបមុខរបរអីដែរលោកយាយកូនយាយ?

ខៈ ធ្វើស្រែដូចតែគ្នា។ ចាំ! ធ្វើតែស្រែ រកស៊ីស្រែចម្ការយើង ដូចថាខ្លះធ្វើកាលីទៅណាំ។ ណុងឯង! ខ្លះគេធ្វើកាលី ធ្វើការខ្លះទៅ។

កៈ ចាំ! ចឹងលោកយាយៗអើ...លោកយាយនៅពេលដែរលលោកយាយរៀបការហ្នឹង ឪពុកម្ដាយជាអ្នកផ្សំផ្គុំអោយ ឬមួយក៏ចិត្តនិងចិត្ត?

ខៈ ចាំ! ខ្លួនឯងចិត្តទៅណាំ! ចាំ។

កៈ ពេលណុងលោកតាបង្គាប់ប៉ុន្មាន? អ៊ូ! អោយថ្លៃបណ្ណាការប៉ុន្មាន?

ខៈ សម័យនោះមិនដែលអោយទេ។ សម័យនោះ មិនបង្គាប់ប៉ុន្មានទេ គ្រាន់តែរៀបការខាងប្រុសគេគិតគេគូទៅ របស់របរគេប៉ុណ្ណោះឯង ដែលមានបង្គាប់រាប់តែពាន់ដូចគេសព្វថ្ងៃទេ សម័យនោះនោះ។ ចាំ! គ្រាន់តែគេដាក់បណ្ណាការទឹកដោះបន្តិចបន្តួច ពីដើមមក១២រៀលនោះ។ ចាំ! ដែលមានដូចគេសព្វថ្ងៃទេ។

កៈ
លោកយាយនៅពេលដែរលោកយាយរៀបការហាសសម័យហ្នឹងគេស្លៀកពាក់ម៉េចដែរ លោកយាយ?

ខៈ ស្លៀកពាក់តែងខ្លួនដូចគេសព្វថ្ងៃទេ។ ចាំ! តែងដូចគេសព្វថ្ងៃ ប៉ុន្តែគេបួងសក់ហាស។

កៈ គេបួងសក់?

ខៈ ចាំ! គេបួងសក់។

កៈ ហើយសំពត់អីអាវអីម៉េចវិញ?

ខ៖ សំពត់អីអាវអីក៏ដូចគ្នាអាវបំពង់វែងចេះ ដៃវែងចេះ។

ក៖ បំពង់ហោស?

ខ៖ អាវបំពង់ អាវបំពង់ច្រកដូចគេសព្វថ្ងៃ គេមានរ៉ូប អើ! សព្វថ្ងៃគេហៅរ៉ូប។

ក៖ អូ៎! ចឹង!

ខ៖ យើងពីមុនគេហៅអាវបំពង់។ ចាំ!

ក៖ ចឹងហោសយាយ?

ខ៖ ចាំ! ច្រកទាំងខ្លួនទាំងអីទៅ ប្លុកទៅ។

ក៖ ចឹង!

ខ៖ ចាំ!

ក៖ អូ៎!

ខ៖ សម័យឥឡូវគេថារកទៅ។

ក៖ លោកយាយ ពេលចង់សួរថាពេលលោកយាយឃើញលោកតាដំបូងហាស លោកយាយធ្លាប់ស្គាល់គ្នាពីមុនមកទេលោកយាយ?

ខ៖ ទេទៅមកៗ ដូចថាគេដើរលេងអីទៅឃើញគាត់ក៏អោយចាស់មកចូលមកសួរទៅណាំ ម៉ែឪចូលមកសួរទៅណាំ។

ក៖ អូ៎! ចឹងលោកយាយ? ចាំ!

ខ៖ ចាំ!

ក៖ ចាំ! ចឹងលោកយាយ លោកយាយអើ! ធ្លាប់រៀនបានថ្នាក់ទីប៉ុន្មានដែរលោកយាយ?

ខ៖ អត់បានរៀនទេ! រៀនថ្នាក់បានទី៣ហ្នឹងពីដើម ប៉ុណ្ណោះឯង។

ក៖ ទី៣?

ខ៖ ចាំ! ទី៣។

ក៖ ទី៣រៀននៅសាលាណាដែរយាយ?

ខ៖ នៅសាលាសណ្ដាន់យើងនេះឯង។

ក៖ សាលាសណ្ដាន់?

ខ៖ សាលាសណ្ដាន់ សាលាទឹកវិល សាលាសណ្ដាន់ហ្នឹង។

ក៖ រៀនបានថ្នាក់ទី៣ ចុះលោកយាយចេះអក្សរអីទេលោកយាយ?

ខ៖ ហើស! សព្វថ្ងៃនៅរៀនធម៌ចេះតិចៗ មើលឃើញ មើលខ្លះ
ប៉ុនសព្វថ្ងៃមើលមិនឃើញទេងងឹតទៅ ហើយ។

ក៖ ចឹងណោះលោកយាយ?

ខ៖ ចាំ!

ក៖ ចាំ! អើ! ពីលោកយាយនៅរៀនហាស
លោកយាយមានមិត្តភក្តិស្និទ្ធស្នាលទេលោកយាយ?

ខ៖ អត់មានទេ! អត់ដែលមានមិត្តភក្តិនឹងគេ។ អត់ដែលមានមិត្តភក្តិនឹងគេទេ មានតែអ្នក
ជិតផ្ទះគ្នាទៅ ក៏ ហៅគ្នាទៅវិញទៅមកប៉ុណ្ណោះឯង ទៅរៀនទាំងអស់គ្នា។
ដល់មិត្តភក្តិជិតស្និទ្ធអត់ដែលមានដូចគេសព្វថ្ងៃ ទេ។ ក្មេងសព្វថ្ងៃ គេមានមិត្តភក្តិណាំ
ប៉ុណ្ណាក៏គេមានមិត្តភក្តិ ខ្ញុំកាលណោះអត់ដែលមានមិត្តភក្តិនឹងគេ ទេ។ ដែងដឹងគ្នាទៅរៀន
មកវិញគេចូលផ្ទះគេទៅ ខ្ញុំទៅផ្ទះខ្ញុំទៅប៉ុណ្ណោះឯង។ អត់ដែលមានទេ។

ក៖ ចាំ លោកយាយ! ហើយចុះពេលលោកយាយទៅរៀនវិញលោកយាយ
ធ្វើដំណើរដោយអីដែលលោកយាយទៅរៀន?

ខ៖ ដើរ យើងដើរជើងនេះឯង។

ក៖ ចាំ!
ខ៖ មិនដែលមានអីជិះទេ។

ក៖ អត់មានអីជិះទេណោះលោកយាយ?

ខ៖ អត់ដែលមានអីជិះទេ។

កៈ ហើយចុះនៅពេលណុងមានសៀវភៅមានអីទេលោកយាយ?

ខៈ មានសៀវភៅ ប៉ុនមិនដែលមានកាបូបយួរដូចគេសព្វថ្ងៃ កាន់!
កាន់ក្តារដាក់សៀវភៅមួយមកដាក់ក្តារ ពីក្រោមដាក់សៀវភៅមក។

កៈ ប៊ិចអត់មាន?

ខៈ មានតែដៃខ្មៅក៏យើងដាក់ហោប៉ាវទៅ ដីសដាក់ហោប៉ាវទៅ ប៉ុណ្ណោះឯង។

កៈ ទៅរៀនទៅ?

ខៈ ទៅរៀនហើយ ក៏ចាយប្រាក់កាលនោះ ក៏មិនដែលមានប្រាក់ទៅរៀនដែរ មានតែ...

កៈ ចុះលោកយាយគិតថាជីវិតឥឡូវ និងពីមុនមានការផ្លាស់ប្តូរអីខ្លះដែរលោកយាយ?

ខៈ អូ៎! ខុសគ្នាឆ្ងាយណាស់។ ខុស! សព្វថ្ងៃគេសម្បូរសប្បាយតាំងពីស្លៀកពាក់
សំពត់ខោអាវយកមិនអស់។ ស៊ីចុកអានេះអានោះយកមិនអស់ យើងពីដើមខ្សត់ណាស់
ខ្សត់រកតែសំពត់នេះផ្លាស់ប្តូរក៏មិនមានទេ។ បានតែបន្ទះរហែក បន្ទះ។ ចាំ!
បន្ទះរកក្រណាត់ផ្សេងមកប៉ះមក ពីដើម។ មិនដែលមាន
សំពត់ខោអាវសម្បូរដូចគេសព្វថ្ងៃទេ។ សព្វថ្ងៃសម្បូរណាស់ សព្វថ្ងៃសម្បូរបែបខោអាវ។

កៈ ចាំលោកយាយ!

ខៈ ចាំ.!

កៈ ចឹងលោកយាយតាំងពីក្មេងរហូតដល់ឥឡូវ
តើលោកយាយចូលចិត្តមុខម្ហូបណាជាងគេដែរ លោកយាយ?

ខៈ អូយ! ដូចម្ហូបអី! មិនដឹង ចូលចិត្តម្ហូបណាទេក្មួយអើយ មិនដឹងចូលចិត្តអាម្ហូបអីហោស
សព្វថ្ងៃវាមិន ដឹងថាមានអីហូបផង។ វាសម្បូរដែរ ប៉ុនទាល់តែយើងមិនសូវមានសាហ៊ុយ។
ចាំ! យើងអ្នកស្រុកស្រែ វា អត់ ខ្សត់ហើយសព្វថ្ងៃយើងដែលរកអីបានទេ
នៅតែផ្ទះពីនាក់តាម៉េកម៉ក់ ប្តីគាត់ឈឺទៀតផង។ ចាំ!

កៈ ចឹងហោសលោកយាយចាំ!

ខៈ ចាំ! ទៅពេទ្យញឹកញាប់ចឹងឯង។ ម្សិលមិញក៏ទៅពេទ្យដែរ។

ក៖ ហើយចុះកូនលោកយាយ...អូ!
ចុះលោកយាយនៅផ្ទះនេះនៅប៉ុន្មាននាក់ដែរលោកយាយ?

ខ៖ នៅតែ២នាក់តា។

ក៖ តែ២នាក់ ចុះកូនទៅណាទៅលោកយាយ?

ខ៖ កូននោះនៅផ្ទះផ្សេងគេនៅនោះ។ ចាំ!

ក៖ លោកយាយមានកូនប៉ុន្មាននាក់ដែរ?

ខ៖ កូនតែ៤។

ក៖ កូន៤?

ខ៖ ចាំ!

ក៖ ចឹងកូនបងឈ្មោះអីដែរលោកយាយ?

ខ៖ កូនបងនោះឈ្មោះ នាង ប្រុស។

ក៖ ហើយបន្ទាប់ទៀត?

ខ៖ បន្ទាប់ទៀតក៏ នាង ផាន នោះនៅផ្ទះនោះ។

ក៖ ផ្ទះណាផ្ទះថ្មនោះ?

ខ៖ នោះផ្ទះខាងជើង។

ក៖ ផ្ទះថ្ម! អូ៎! ផ្ទះឈើណុងហោស?

ខ៖ ចាំ!

ក៖ ហើយចុះបន្ទាប់ទៀតលោកយាយ?

ខ៖ បន្ទាប់ទៀតគឺ សារឿន ប្រុស ទីពីរគឺបន្ទាប់មកទៀត គឺក្រោយគេគឺសារិទ្ធប៉ុណ្ណោះឯង។

ក៖ ហើយចុះពួកគាត់មានគ្រួសារអស់ហើយលោកយាយ?

ខ៖ មានអស់ហើយ ចំណាស់រៀងខ្លួន។

កៈ ហើយចុះពួកគាត់ប្រកបមុខរបរអីដែរលោកយាយ?

ខៈ ប្រកបមុខរបរទៅធ្វើការលីទៅធ្វើអីគេណា ទៅធ្វើកាលីដូចថាធ្វើតាមហាងតាមអី អាខ្លះធ្វើចម្លាក់ធ្វើអីទៅណាំ។ ចាំ! ធ្វើការងារចេះតែដើររកទៅណាំ។

កៈ ចឹង!

ខៈ គ្រាន់បានប្រាក់ចាយខ្លះ។

កៈ ហើយចុះលោកយាយឥឡូវសព្វថ្ងៃលោកយាយមានចៅប៉ុន្មានដែរលោកយាយ?

ខៈ ចៅ?

កៈ ចាំ!

ខៈ ចៅមិនសូវច្រើនទេ ចៅមើលអោយរាប់មើលរាប់អោយស្តាប់។

កៈ ចាំ!

ខៈ ប្រាំពីរ ប្រាំបួន ចៅប្រាំបួន ចៅដប់ពីរណុងឯង។

កៈ ចៅដប់ពីរនាក់លោកយាយ?

ខៈ ចាំ!

កៈ អូ៎! ចៅ១២នាក់?

ខៈ អត់សូវច្រើនទេ ខ្លះគេចៅហា ហុកសិប។

កៈ អូ៎! ចៅដប់ពីរអត់សូវច្រើនទៀតលោកយាយ។

ខៈ អត់សូវច្រើនទេ។

កៈ ចាំ!

ខៈ ចាំ!

កៈ ចឹងលោកយាយអើ! ក្រៅពីភាសាខ្មែរ លោកយាយចេះភាសាអីទៀតទេលោកយាយ?

ខ៖ អត់! មានដែលមានចេះអីទេ។ ចុះយើងមិនបានទៅរៀនហោស ដូចថាយើងអើ! សម័យដូចថាមនុស្ស ពីដើមមិនងាយ ដល់គេមកសង្គមសម្បូរសប្បាយចេះទៅ យើងក៏មិនដែលបានទៅណាចាស់ផង នៅតែ តេកតុកតាមផ្ទះ បាយទឹកទិញស្រូវទិញអង្ករគេស៊ីទៅស្រែក៏ធ្វើមិនកើត។

ក៖ អូ! លោកយាយអត់មានស្រែទេហោស?

ខ៖ មានស្រែ! មិនអត់ ប៉ុន្តែធ្វើមិនកើត កម្លាំងវាគ្មាន។

ក៖ អូ! អោយកូនធ្វើ?

ខ៖ ចាំ! អោយកូនចៅគេធ្វើទៅ កូនចៅខ្លះក៏ធ្វើ ខ្លះក៏ចោល ទិញតែអង្ករ ទិញតែស្រូវគេស៊ីទេ យាយតាអី។

ក៖ ចឹងហោសចាំ!

ខ៖ ចាំ!

ក៖ ហើយចុះលោកយាយ អើ! លោកយាយដឹងថានរណាគេនៅក្នុងផ្ទះលោកយាយចេះឧបករណ៍ភ្លេងទេចេះលេងឧបករណ៍ភ្លេងទេ?

ខ៖ អត់ទេ! គ្មានទេ អត់ចេះទេអារឿងភ្លេង។

ក៖ អត់ចេះទេហោស?

ខ៖ ចាំ! អត់ចេះទេ។

ក៖ លោកយាយចុះផ្ទះរបស់លោកយាយសាងសងតាំងពីឆ្នាំណាដែរលោកយាយ?

ខ៖ អូ! ដូចជាមិនបានចាំណា។ វាមិនបានជាគិតដែរ។ យូរដែរ!

ក៖ តាំងពីយូរហើយហោស?

ខ៖ យូរដែរ!

ក៖ ចាំ! នរណាអ្នកសាងសងដែរផ្ទះមួយហ្នឹង?

ខ៖ សាងសងតានេះឯង គាត់សាងសង។

ក៖ ធ្វើតែម្នាក់ឯងហោស?

ខ៖ ទេ! យើងទិញឈើទិញអីមក យើងជួលរកគេធ្វើណា៎ពីដើមមកថារកគេណា៎ ដែលមានជួល មានប្រាក់ជួលទេ រកគ្នាអារឈើអារអីខ្លួនឯងទៅ រកគេជួយធ្វើទៅ មួយថ្ងៃ ពីរថ្ងៃ បីថ្ងៃក៏រួចទៅណា៎។

ក៖ ចា៎! លោកយាយចា៎!

ខ៖ ចា៎!

ក៖ ហើយចុះចឹងឧបករណ៍ដែលសាងសងផ្ទះនេះមានដូចជាសម្ភារៈអីខ្លះដែរលោកយាយ? ចា៎! ដោយសារតែផ្ទះពីដើមចឹងហាសឧបករណ៍សាងសងចឹងហាស?

ខ៖ ទេសាងសងនោះមានតែដែកឈូសហ្នឹងរណាហ្នឹងឯង។

ក៖ ឈើអីដែរលោកយាយ?

ខ៖ អើ!ឈើហ្នឹងហើយ។

ក៖ ឈើនេះឈើអីដែរលោកយាយ?

ខ៖ ឈើដើមយាង។

ក៖ អូយ! ល្អហាសលោកយាយណា៎?

ខ៖ ចា៎! ដើមយាង។

ក៖ ដូចជាអត់មានឃើញបាក់បែកសោះ?

ខ៖ អត់ណា! ផ្ទះនេះយូរគ្រាន់ដែរ ប្រហែលជា៣០ឆ្នាំហើយទេដឹងយ៉ាង។

ក៖ អូយ! ហើយ....

ខ៖ មេស៊ីចង់អស់ហើយ។

ក៖ ខ្ញុំគិតថាវាល្អនៅល្អ។

ខ៖ មិនសូវជាល្អទេ កន្លែងខ្លះចង់មេស៊ីទៅហើយ។

ក៖ ចឹងហោសលោកយាយ! លោកយាយកំណើតកើតជានៅហ្នឹងម៉ងហោសយាយ?

ខ៖ ចា៎! នៅនេះឯង។

ក៖ ចុះលោកយាយអាចប្រាប់ពីដល់វគ្គពីខ្សែជីវិតលោកយាយហាសណា៎។ កាលពីក្រមុំលោកយាយជួប ការលំបាកអីខ្លះដែរ?

ខ៖ កាលពីក្រមុំការលំបាកហ្នឹងឯង រកស៊ីតែជើងដើរ មិនដែលមានអីជិះទេ។ កង់ក៏មិនចេះជិះនឹងគេ បើសម័យគេមានកង់ក៏អត់ចេះជិះ អត់ចេះជិះរហូតមកសព្វថ្ងៃ។ រកស៊ីរែកអីៗក៏ជើងដើរហ្នឹងឯង មិនដែលបានមានអីជិះ ព្រោះយើងមិនចេះជិះផង ក៏ដើរ។

ក៖ ចា៎! ហើយចុះពីសម័យ ប៉ុល ពត វិញលោកយាយ លោកយាយអាយុប៉ុន្មានឆ្នាំដែរ?

ខ៖ សម័យ ប៉ុល ពត ប្រហែលជា...សម័យប៉ុលពតប៉ុន្មានឆ្នាំហើយមកនេះ ម្ភៃជាងហើយសាមសិបទេ?

ក៖ ចា៎!

ខ៖ អើ! គិតមើល យើងប្រហែលអាយុសែលើស មិនទាន់...ហា(៥០)ហើយទេយ៉ាង កាលសែ(៤០)...កាលប៉ុលពត ប៉ុលពតមកប៉ុននេះប៉ុន្មានសាបសិបឆ្នាំទេអី សាមសិបឆ្នាំហើយ។ ចា៎! យើងប្រហែលជាសែសិបលើសហ្នឹងឯង។ អូ! ប៉ុលពតពិបាកហ្នឹងឯង ក្រណាស់គ្មានអីស៊ីទេ។

ក៖ ហើយម៉េចទៀតលោកយាយពិបាកអីខ្លាំង គេប្រើលោកយាយធ្វើអីខ្លះដែរ?

ខ៖ អ៊ូ!

ក៖ ពេលណុងលោកយាយអាយុប៉ុន្មានដែរនៅសម័យណុងហាស?

ខ៖ ប្រហែលជាសែលើសហ្នឹងឯង។

ក៖ សែជាងហោសលោកយាយ?

ខ៖ ចា៎! សែជាង។

ក៖ អ៊ូ! ពេលណុងលោកយាយមានកូនអត់?

ខ៖ កូន! កូនតូច។

កៈ កូនពេលណុងកូនលោកយាយ?

ខៈ កូនអត់សូវមានធំទេសម័យនោះកូននៅតូចៗ។

កៈ នៅតូចៗទាំងអស់ហោស?

ខៈ កូននៅតូចៗ។

កៈ ប្រហែលជាអាយុប៉ុន្មានឆ្នាំដែរកូនលោកយាយ?

ខៈ កូនតូចៗអាខ្លះអាយុដប់ប្រាំទៅ អាបងទៅ អាក្រោយ អាក្រោយគេនោះ មីស្រី មីនៅផ្ទះខាងជើងនោះប្រហែលជាអាយុប្រាំពីរប្រាំបីឆ្នាំ ប្រាំបីឆ្នាំ។

កៈ ពេលហ្នឹងគេប្រើលោកយាយធ្វើអីខ្លះដែរលោកយាយ?

ខៈ ប្រើឱ្យរកជី ធ្វើយើងដូចថាយើងរកកន្ត្រាំងខែតរកអីធ្វើជី ស្ទូងដក លើកភ្លឺ ហ្នឹងឯង កាន់ចប់លើកភ្លឺដកសំណាបរាប់ផ្លូន។

កៈ ចឹងហោសលោកយាយ!

ខៈ ជួនណាដកមិនបានគ្រប់ផ្លូនគេកំណត់ណុងតែម្នាក់ពីរផ្លូនមិនបានអត់បបរស៊ីទៅ។ ចាំៗ អត់បបរស៊ីបើសិនជាណាបានគ្រប់ផ្លូននឹងគេ ក៏បានបបរមួយវែកទៅ បើមិនបានគ្រប់ផ្លូនទេក៏...

កៈ ហើយចុះពេលណុងកូនលោកយាយមានប៉ុន្មាននាក់ដែរ?

ខៈ កាលនោះមានតែបួនណុងឯង។ ចាំ! នៅបួនហ្នឹងឯង នៅតូចៗនោះ អាតូចៗដែលថាមួយនោះងាប់អស់ នៅតូចៗហ្នឹងឯថង។

កៈ តូចៗ! កាលហ្នឹងកើតមុន ប៉ុល ពត ឬក៏នៅជិតសម័យប៉ុលពត?

ខៈ ប៉ុលពតនោះ កើតអាក្រោយប៉ុលពតនោះមួយ អាកណ្តាលប៉ុលពតនោះមួយ ងាប់ទាំងអស់។

កៈ ស្លាប់ទាំងអស់?

ខៈ ស្លាប់ទាំងអស់។

កៈ ទាល់តែឆ្នាំណាទៅទើបមានកូនម្តងទៀត ហើយនៅរស់រហូត?

ខៈ អាក្រោយនេះ អាប្អូននេះ អាសារិទ្ធនេះ ។ ចាំ!

កៈ អូ៎!

ខៈ បានរស់ទៅ។

កៈ ចឹងហោសលោកយាយ?

ខៈ ចាំ! មួយនេះឯង។

កៈ ចឹងនៅពេលដែល
ពេលអំឡុងពេលណុងលោកយាយកំពុងតែធ្វើការហើយកូននៅឆ្ងាយទៀត។

ខៈ ហ្នឹងហើយ!

កៈ ចឹងកូនពិបាកខ្លាំងលោកយាយ?

ខៈ កូនក៏មានយាយចាស់មើល មានយាយចាស់គេអោយមើល
គេអោយមើលកូនចឹងហាស ទម្រាំតែបានម៉ែមកវិញនោះក៏កូនយំទំហឹងចង់ដាច់ខ្យល់
ចុះយាយមានអីអោយមឹម។

កៈ អូ៎!

ខៈ ម៉ែទៅរស់ឆ្ងាយ ទៅធ្វើការឆ្ងាយ។

កៈ ពេលណុងអាណិតកូនហាសលោកយាយ?

ខៈ បញ្ហាគេចុះឯង គេអោយយើងទៅរកចុះឯង។

កៈ ចាំ! ហើយទៅដល់ពេលដាច់សម័យប៉ុលពតហើយ
ចូលសម័យស្រួលបួលវិញហាសណាំលោកយាយ
ពេលដែលដាច់សម័យប៉ុលពតភ្លាមមកវិញអត់មានអីទេមែនទេលោកយាយ?

ខៈ មានតែបាតដៃទទេ ចាំ! អត់មានអីទេ។

កៈ ហើយពីរនាក់ប្តីប្រពន្ធធ្វើម៉េចទៅលោកយាយ?

ខ៖ ទេចេះតែរកទៅណា៎ មិនដឹងធ្វើម៉េចទេ រកធ្វើជាលធ្វើអី បេះនេះបេះនោះស្លដាំ។

ក៖ មកពេលណុងធ្វើដំណើរពីណាមកណាវិញលោកយាយ?

ខ៖ ខ្ញុំប៉ុលពតទៅនៅនោះមាននៅនេះណា។

ក៖ នៅណាដែរលោកយាយ?

ខ៖ នៅគេហៅភូមិទឹកថ្លា។ ភូមិទឹកថ្លា ឯត្បូងនោះ មករកស្រុកចាស់វិញ មកភូមិចាស់វិញ ពីដើមមិញនៅនេះឯង ហើយគេជម្លៀសទៅឆ្ងាយទៅក៏ទៅនៅភូមិនោះទៅ មកនៅនេះវិញ ស្រាវជ្រាវមើលមានអីទទេហ្នឹងហើយ មានឆ្នាំងបាយមួយ។

ក៖ ហើយហ្នឹងយកកូនមកពីរនាក់?

ខ៖ ចា៎! កូនរម៉េករម៉កមួយទៅណា៎ ហ្នឹងឯង។

ក៖ ចា៎!

ខ៖ មិនដឹងធ្វើយ៉ាងម៉េច វាកម្សត់ហើយ អោយតែមានដង្ហើម ចេះតែរកទៅណា៎ ជីកក្តួចជីកដំឡូងទៅណា៎ មានអី។

ក៖ ហើយពិបាកខ្លាំងទេ?

ខ៖ អូ៎! ពិបាកខ្លាំងហ្នឹងឯង ទម្រាំបានរស់ បានប៉ុណ្ណេះ មិនដឹងធ្វើម៉េច។

ក៖
ហ្នឹងហើយលោកយាយដល់ពេលចឹងមកដល់ពេលអើហើយដល់ពេលណុងដល់ពេលចប់សម័យប៉ុល ពតភ្លាមមកវិញមានផ្ទះទេលោកយាយពេលណុង?

ខ៖ មានផ្ទះពីណា។

ក៖ អត់មានទេ?

ខ៖ ផ្ទះដែលនៅជម្លៀសចោល មានតែកូនខ្ទមនៅទឹកថ្លាឯនោះ ក៏រើពីនោះឯងមកធ្វើអីនេះ។

ក៖ មកធ្វើហ្នឹងឯង?

ខ៖ ចាំ!

ក៖ ចឹងដីហ្នឹង ដីតាំងពីជីដូនជីតាមកហើយ?

ខ៖ ជីដូនជីតាមកគាត់ដុតព្រៃទេ រាល់ថ្ងៃដុតព្រៃនាំគ្នាគាស់កកាយធ្វើជាភូមិទៅ ធ្វើជាផ្ទះទៅក៏គេជម្លៀសទៅ នោះដល់មកវិញមកកន្លែងចាស់វិញ។

ក៖ អើ! ចឹងហោសលោកយាយ។ អ៎! ហើយទៅដល់ពេលចឹង ហើយដល់ពេលអើ! សម័យស្រួលបួលហើយ
ហើយលោកយាយរកមុខរបរអីដើម្បីចិញ្ចឹមកូនៗហាសលោកយាយ?

ខ៖ ចេះតែប្រឹង។

ក៖ ធ្វើអីទៅ?

ខ៖ ជីកដំឡូង ជីកក្តួច រកបោចល្មៀកបោចស្មីធ្វើជាលលក់ទិញទៅណាំ មានគេរកទិញតិចៗ ចេះតែត្បាលជាលលក់ទៅ ក៏ចេះតែធ្វើចិញ្ចឹមកូនទៅណាំ ហ្នឹងឯង ធ្វើចឹង។

ក៖ ចឹងកូនលោកយាយបានចូលរៀនទេ?

ខ៖ ចូលរៀនខ្លះដែរ មិនសូវបានជាថ្នាក់ធំទេ ថ្នាក់ទី៦ ទី៥ ប៉ុណ្ណោះឯង។

ក៖ ចឹងហោសលោកយាយ?

ខ៖ ចុះម៉ែឪក្រនោះបានប្រាក់ពីណាអោយកូនទៅរៀន។ ចាំ!

ក៖ ចាំ!
ចឹងលោកយាយក្នុងជីវិតរបស់លោកយាយបទពិសោធន៍ល្អអីខ្លះដែរលោកយាយចង់ផ្តាំទៅកូនៗ ហាសណាំ?

ខ៖ អោយវាល្អ។

ក៖ អោយស៊ូទ្រាំម៉េច?

ខ៖ ស៊ូទ្រាំអោយ ស៊ូទ្រាំដែលសម័យកាលលំបាកមកនេះ ស៊ូទ្រាំផុតទៅហើយ។ សម័យនេះគេសម្បូរសប្បាយខំប្រឹងរកស៊ី ខំប្រឹងធ្វើគំនិតល្អណាំ ហ្នឹងឯង ធ្វើគំនិតល្អ

កសាងជីវិតអោយ ទៅអោយបានសង្គម គេសម្បូរសប្បាយចេះហើយ ហ្នឹងឯង ខំកសាងជីវិតអោយល្អ កុំអោយជីវិតភ្លើតភ្លឺន ហ្នឹងហើយក្មេងក្មាងអីកុំអោយវាដើរភ្លើតភ្លើន ដើរខូច ដើរជក់ ពិបាកណាស់ឯង ខំប្រឹងរកស៊ីទៅ ស្រុកគេសម្បូរសប្បាយហើយនោះ នាងណា៎។

ក៖ ចា៎ លោកយាយ!

ខ៖ ហ្នឹងឯង!

ក៖ ចឹងចង់អោយកូនចៅលោកយាយអើ ជៀសវៀងពីអំពើអបាយមុខអីខ្លះដែរលោកយាយ?

ខ៖ ចា៎! ជៀសវាអំពើអបាយមុខ ផឹកស៊ី អារឿងល្បែង អារឿងផឹកជក់សព្វថ្ងៃមិនបាច់អោយមានស្វាវមានអី អោយឈប់ទៅអោយកាន់តែអំពើល្អ ធ្វើបុណ្យធ្វើទានចេះធ្វើបុណ្យធ្វើទានទៅបានអំពើល្អ បានបាន សុខ។

ក៖ ចា៎! អោយពួកគាត់ចំប្រឹងអីខ្លះដែរលោកយាយ?

ខ៖ អោយខំប្រឹងរៀន ណុងឯង អោយបានចេះ អោយបានជួយសង្គមណុងហើយ។

ក៖ ចា៎!

ខ៖ បានសង្គមរីកចម្រើនតទៅមុខទៀត ហ្នឹងឯង។

ក៖ ចឹងហោសលោកយាយចា៎?

ខ៖ ចា៎!

ក៖ ចឹងអរគុណហើយ!

ខ៖ ចា៎!

ក៖ ជាចុងក្រោយចឹងហោសលោកយាយ។ ចា៎!

ខ៖ ចា៎!

កៈ ចឹងអរគុណលោកយាយ

ពាក្យពេចន៍លោកយាយពិតជាល្អមែនទែនសម្រាប់ដល់កូនចៅជំនាន់ក្រោយទៀតអោយពួកគាត់បានយល់អោយពួកគាត់បានដឹងអំពីជីវិតរបស់លោកយាយចឹងហាសលោកយាយ។

ខៈ ចាំ!

កៈ ចឹងលោកយាយព្រមអោយ

ខ្ញុំដាក់ការសម្ភាសរបស់លោកយាយដាក់ចូលក្នុងវេបសាយសាលាទេលោកយាយ?

ខៈ ចាំ! ដាក់ចុះ ធ្វើម៉េចដាក់ក៏ដាក់ទៅមានថាអីយកហើយ ផ្សាយក៏ផ្សាយទៅ។

កៈ ចាំ! អរគុណលោកយាយ!

ខៈ យាយមានថាអី។

កៈ ចាំ! អរគុណច្រើនលោកយាយ៕